ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ

# របាយការណ៍សង្ខេបនៃការអនុវត្តការងារប្រចាំឆ្នាំ របស់អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ

ឆ្នាំ២០២៥

# មាតិកា


I. **សេចក្តីផ្តើម**

១. អំពីគោលបំណង

២. អំពីគោលដៅ

II. **វឌ្ឍនភាពការងារ**

១. កម្មវិធីអប់រំ

២. កម្មវិធីការងារ

៣. កម្មវិធីកសិកម្ម

III. **បញ្ហាប្រឈម និងដំណោះស្រាយ**

១. បញ្ហាប្រឈម

១.១ បញ្ហាប្រឈមផ្នែកអប់រំ

១.២ បញ្ហាប្រឈមផ្នែកការងារ

១.៣ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ

២. ដំណោះស្រាយ

២.១ ដំណោះស្រាយផ្នែកអប់រំ

២.២ ដំណោះស្រាយផ្នែកការងារ

២.៣ ដំណោះស្រាយផ្នែកហិរញ្ញវត្ថុ

IV. **ទិសដៅ និងវិធានការណ៍**

V. **សន្និដ្ឋាន**

VI. **ឧបសម្ព័ន្ធ**

## I. សេចក្តីផ្តើម

អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ ជាអង្គការក្រៅរដ្ឋាភិបាល ដែលបានបង្កើតក្នុងគោលបំណង និងគោលដៅ ដូចខាងក្រោមៈ

**១. អំពីគោលបំណង**

- បណ្តុះបណ្តាលភាសាបរទេសនិងកុំព្យូទ័រដល់យុវជនខ្មែរនៅតាមទីជនបទដោយមិនបង់ថ្លៃសិក្សា
- បង្រៀននូវជំនាញបច្ចេកទេស វិជ្ជាជីវៈ ដល់សិស្ស និស្សិត ដែលគ្មានសមត្ថភាពបង់ថ្លៃសិក្សា
- ចូលរួមលើកទឹកចិត្តដល់សិស្ស និស្សិតក្នុងការបន្តការសិក្សា និងការអភិវឌ្ឍសមត្ថភាព ដើម្បីភាពជោគជ័យ
- ជួយជាសម្ភារសិក្សាដល់សិស្ស និស្សិត ដែលគ្មានលទ្ធភាព
- ជួយស្វែងរកការងារសមរម្យឲ្យដល់ប្រជាជនខ្មែរ ដើម្បីកាត់បន្ថយការចំណាកស្រុក និងចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិ។

**២. អំពីគោលដៅ**

- យុវជនមានចំណេះដឹងផ្នែកកុំព្យូទ័រ និងភាសាបរទេសច្បាស់លាស់ និងអាចប្រើប្រាស់ក្នុងការងារ
- ធ្វើឲ្យសិស្ស និស្សិតទទួលបានការអប់រំ និងមាននូវជំនាញវិជ្ជាជីវៈច្បាស់លាស់។

## II. ចង្អុលភាពការងារ

### ១. កម្មវិធីអប់រំ

កម្មវិធីអប់រំរបស់ អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ បានសហការជាមួយ សាលារៀន សាលាឃុំ វត្តព្រះពុទ្ធ ព្រះវិហារកាតូលិក អង្គការ និងសហគមន៍ផ្សេងៗទៀត បើកបង្រៀនកុំព្យូទ័រ ភាសាអង់គ្លេស និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ផ្សេងៗ ដល់សិស្សនិស្សិត យុវជន និងពលរដ្ឋនៅក្នុងតំបន់។

| ល.រ | ឈ្មោះមណ្ឌល | ចំនួនគ្រូ | ជំនាញសិក្សា | ចំនួនកុំព្យូទ័រ | ចំនួនសៀវភៅកូពី | ចំនួនសិស្សចុះឈ្មោះ | ចំនួនសិស្សបញ្ចប់វគ្គសិក្សា | ទីតាំង | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| 1 | កំពង់ស្វាយ | 2 | ភាសាអង់គ្លេស និងកុំព្យូទ័រ | 30 | 536 | 572 | 209 | នៅក្នុងសាលាបឋមសិក្សាទួលក្បិល, ភូមិទៀមចាស់ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ | |
| 2 | តាស្នែ | 2 | ភាសាអង់គ្លេស និងកុំព្យូទ័រ | 30 | 602 | 777 | 309 | នៅសាលាបឋមសិក្សាតាស្នែ, ភូមិតាស្នែ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប | |
| 3 | ដានរុន | 2 | ភាសាអង់គ្លេស និងកុំព្យូទ័រ | 25 | 584 | 693 | 234 | នៅក្នុងវត្តមុនធ្យាន, ភូមិដានរុន ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប | |
| 4 | តាយ៉ែក | 2 | ភាសាអង់គ្លេស និងកុំព្យូទ័រ | 30 | 894 | 1075 | 543 | នៅក្នុងវត្តតាយ៉ែកឯករង្សី, ភូមិតាយ៉ែក ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប | |
| 5 | ថ្នល់ | 2 | ភាសាអង់គ្លេស និងកុំព្យូទ័រ | 25 | 730 | 1045 | 508 | នៅក្លឹបយុវជនអង្គការទស្សនៈពិភពលោក, ភូមិថ្នល់ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 6 | ស្ទឹងព្រះស្រុក | 4 | ភាសាអង់គ្លេស និង កុំព្យូទ័រ | 50 | 865 | 1603 | 512 | នៅក្នុងសាលាបឋមសិក្សាស្ទឹងព្រះស្រុក, ភូមិស្ទឹងព្រះស្រុក ឃុំល្វា ស្រុកពួក ខេត្តសៀមរាប | |
| 7 | បល្ល័ង្ក | 2 | កុំព្យូទ័រ | 30 | 0 | 1475 | 683 | នៅក្នុងវិទ្យាល័យហ៊ុបសែនបល្ល័ង្ក, ភូមិបល្ល័ង្ក សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | |
| 8 | គោល | 2 | ភាសាអង់គ្លេស និង កុំព្យូទ័រ | 25 | 436 | 673 | 339 | នៅក្នុងសាលាបឋមសិក្សាបញ្ចគោល, ភូមិគោល ឃុំពពេល ស្រុកសូទ្រនិគម ខេត្តសៀមរាប | |
| 9 | ប្រាសាទធ្មង់ | 2 | ភាសាអង់គ្លេស និង កុំព្យូទ័រ | 30 | 733 | 1093 | 525 | នៅក្នុងវត្តប្រាសាទធ្មង់, ភូមិម្កាក់ ឃុំតាសោម ស្រុកអង្គរជុំ | |
| 10 | កៀនសង្កែ | 1 | កុំព្យូទ័រ | 25 | 0 | 435 | 146 | នៅក្នុងវិទ្យាល័យកៀនសង្កែ, ភូមិសាលាកកោះ ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប | |
| 11 | បាវិត | 2 | កុំព្យូទ័រ និងសរសេរកូដ | 80 | 0 | 2945 | 1372 | នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបាវិត, ក្រុងបាវិត ខេត្តស្វាយរៀង | |
| 12 | ជម្ពូវ័ន | 5 | កុំព្យូទ័រ និងសរសេរកូដ | 75 | 0 | 893 | 346 | នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ហ៊ុន សែន ជម្ពូវ័ន, ភ្នំពេញ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 13 | អង្គរជុំ | 2 | កុំព្យូទ័រ | 30 | 0 | 656 | 627 | នៅវិទ្យាល័យអង្គរជុំ, ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប | |
| 14 | បន្ទាយឆ្មារ | 4 | កុំព្យូទ័រ | 50 | 0 | 1726 | 850 | នៅវិទ្យាល័យបន្ទាយឆ្មារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ | |
| 15 | រកា | 2 | ភាសាអង់គ្លេស និង កុំព្យូទ័រ | 30 | 517 | 1012 | 343 | នៅក្នុងសាលាបឋមសិក្សារកា, ភូមិរកា ឃុំល្វា ស្រុកពួក ខេត្តសៀមរាប | |
| 16 | ប្រវ៉ាល | 2 | ភាសាអង់គ្លេស និង កុំព្យូទ័រ | 25 | 491 | 706 | 439 | នៅក្នុងសាលាបឋមសិក្សាប្រវ៉ាល ភូមិប្រវ៉ាល ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប | |
| 17 | ព្រះសីហនុ | 2 | កុំព្យូទ័រ | 50 | 0 | 846 | 366 | នៅក្នុងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ | |
| 18 | នគរធំ | 1 | សរសេរកូដ | 25 | 0 | 151 | 0 | នៅក្នុងវិទ្យាល័យនគរធំ, សង្កាត់នគរធំ, ខេត្តសៀមរាប | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 19 | ខេ ឌី អិម អ | 2 | ភាសាអង់គ្លេស និង កុំព្យូទ័រ | 25 | 317 | 317 | 0 | នៅក្នុងអនុវិទ្យាល័យឈើទាល, ភូមិតារាក់, ឃុំឈើទាល, ស្រុកស្វាយជ្រំ, ខេត្តស្វាយរៀង | |
| | **សរុប** | **43** | | **690** | **6,705** | **18,693** | **8,351** | | |

## ២. កម្មវិធីការងារ

កម្មវិធីការងារ របស់អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន យើងខិតខំធ្វើចលនាបំផុសស្មារតីប្រជាពលរដ្ឋឱ្យងាកមកចាប់អារម្មណ៍ធ្វើការងារក្នុងប្រទេស ចៀសវាងទៅធ្វើការដោយខុសច្បាប់នៅក្រៅប្រទេស ដែលជាកត្តាប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗ ពីព្រោះការងារក្នុងប្រទេសកម្ពុជាក៏សម្បូររួមនឹងប្រាក់ខែក៏ប្រហាក់ប្រហែលនឹងប្រទេសក្បែរខាងយើងដែរ ដោយយើងបានជួយប្រឹក្សាការងារបានចំនួន១៣០០នាក់ និងរកការងារជូនយុវជនបានធ្វើចំនួន ៧៦នាក់។ យើងក៏បានសហការជាមួយទីភ្នាក់ងារជាតិ មុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះផ្សព្វផ្សាយឱកាសការងារក្នុងប្រទេសជូនដល់ពលករត្រឡប់មកពីថៃវិញផងដែរ។

## ៣. កម្មវិធីកសិកម្ម

ស៊ីថេបបានរៀបចំកម្មវិធីទស្សនកិច្ចស្វែងយល់ពីបច្ចេកទេស និងបច្ចេកវិទ្យាកសិកម្មជូនសហគមន៍កសិកម្មតាសីសាមគ្គី ដែលស្ថិតក្នុងខេត្តបាត់ដំបង ដោយលើកទី១ទៅតៃវ៉ាន់ និងលើកទី២ ទៅវៀតណាម។ ដំណើរទស្សនកិច្ចផ្តោតសំខាន់ទៅលើ គុណភាពគ្រាប់ពូជបន្លែ គ្រឿងយន្តកសិកម្ម ផ្ទះសំណាញ់ និងគំរូផ្សារបោះដុំបន្លែ។








## III. បញ្ហាប្រឈម និងដំណោះស្រាយ

### ១. បញ្ហាប្រឈម

### ១.១ បញ្ហាប្រឈមផ្នែកអប់រំ

- សិស្សអវត្តមានច្រើនដោយសារកត្តាទឹកជំនន់លិចផ្លូវទៅសាលារៀននៅក្នុងរដូវវស្សា បញ្ហាជំងឺ ជួយធ្វើស្រែចំការឪពុកម្តាយ និងម៉ោងត្រួតគ្នាពេលដែលខាងសាលារដ្ឋធ្វើការប្រឡងប្រចាំខែ។
- ការចូលរួមនិងយល់ដឹងពីតម្លៃនៃការសិក្សារបស់អាណាព្យាបាលនៅមានកម្រិត ក្នុងការជួយជំរុញកូនៗអោយមករៀន។
- អត្រាសិស្សបោះបង់ច្រើនព្រោះមានការប៉ះម៉ោងដូចគ្នានៅសាលារដ្ឋ នៅចន្លោះខែវិច្ឆិកា ដល់ខែមករានិងសិស្សមួយចំនួនបានផ្លាស់ប្តូរទីលំនៅ។

### ១.២ បញ្ហាប្រឈមផ្នែកការងារ

- តាមបណ្តារោងចក្រ សហគ្រាស ទទួលយកតែកម្មការិនីភាគច្រើន ដែលជាហេតុធ្វើឱ្យបុរសពិបាករកការងារធ្វើ
- តាមបណ្តារោងចក្រ សហគ្រាស នៅតាមខេត្តភាគច្រើន ទទួលយកតែកម្មការិនី មានជំនាញ និងចេះអក្សរ
- ពលករត្រឡប់មកថៃខ្វះឯកសារក្នុងការចូលធ្វើរោងចក្រ
- ការវិលត្រឡប់របស់ពលករពីថៃយ៉ាងគំហុក ធ្វើឱ្យពិបាកផ្គូផ្គងការងារជូនបានទាន់ពេល
- សាលាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅតែក្នុងទីក្រុងនិងទីប្រជុំជន
- យុវជនចង់បានការងារធ្វើភ្លាមៗ ជាជាងការរៀនយកជំនាញ
- កម្មករដែលចូលធ្វើការហើយ លាឈប់ពីកន្លែងការងារជាញឹកញាប់

### ១.៣ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ

ម្ចាស់ជំនួយយល់ឃើញថា ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដូច្នេះមូលនិធិជាច្រើនត្រូវម្ចាស់ជំនួយបង្វែរទៅជួយប្រទេសផ្សេង ដែលជាហេតុជំនួយហិរញ្ញវត្ថុត្រូវបានកាត់បន្ថយយ៉ាងខ្លាំង និងធ្វើឱ្យសកម្មភាពជាច្រើនត្រូវកាត់បន្ថយ និងរាំងស្ទះដល់ផែនការអភិវឌ្ឍគម្រោងថ្មីៗ។ បន្ថែមលើសពីនេះ គឺប្រទេសកម្ពុជាយើង កំពុងមានបញ្ហារឿង scammer ដែលធ្វើឱ្យម្ចាស់ជំនួយកាន់តែពិបាកផ្តល់ជំនួយ។

## ២. ដំណោះស្រាយ

### ២.១ ដំណោះស្រាយផ្នែកអប់រំ

- បន្តពង្រឹងច្បាប់វិន័យក្នុងថ្នាក់រៀន ប្តូរម៉ោងសិក្សាឬដាក់បញ្ចូលជាមួយថ្នាក់ផ្សេងដែលមានកម្រិតដូចគ្នា ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអាណាព្យាបាល និងស្ថាប័នពាក់ព័ន្ធអោយជួយជំរុញ ក៏ដូចជាពន្យល់ណែនាំសិស្សានុសិស្សមករៀនអោយទៀងទាត់។
- អញ្ជើញអាណាព្យាបាលចូលរួមរាល់កម្មវិធីប្រកួតប្រជែងរបស់សិស្សានុសិស្ស កម្មវិធីបិទវគ្គសិក្សាធ្វើការចែករំលែកភាពជោគជ័យដែលបង្ហាញថា ការសិក្សាធ្វើឱ្យមានឱកាសល្អក្នុងអនាគត។

- រៀបចំម៉ោងពេលបន្ថែមសម្រាប់សិស្សដែលអាចដូរម៉ោងរៀន បញ្ចូលសិស្សទៅតាមកម្រិតដែលដូចគ្នា ឬធ្វើនៅតាមថ្នាក់ដែលកម្រិតដូចគ្នា។

### ២.២ ដំណោះស្រាយផ្នែកការងារ

- ខិតខំស្វែងរកកិច្ចសហការពីរោងចក្រ សហគ្រាស ឲ្យទទួលយកកម្មករបុរស
- ជំរុញឲ្យកម្មករ កម្មការិនីមករៀនជំនាញ មុននឹងបញ្ជូនទៅរោងចក្រ
- ព្យាយាមពន្យល់យុវជន និងឪពុកម្តាយឲ្យយល់ពីអត្ថប្រយោជន៍ការងារនៅក្នុងស្រុក
- សហការជាមួយមជ្ឈមណ្ឌលការងារខេត្តនីមួយៗនិងអាជ្ញាធរដើម្បីផ្សព្វផ្សាយការងារ
- សហការជាមួយសាលាបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដោយជំរុញឱ្យយុវជនចូលរៀនជំនាញ
- ក្រសួងការងារបានចេញសេចក្តីប្រកាសឱ្យរោងចក្រ សហគ្រាសទទួលយកពលករដែលមកពីថៃវិញទោះមិនទាន់មានឯកសារគ្រប់គ្រាន់

### ២.៣ ដំណោះស្រាយផ្នែកហិរញ្ញវត្ថុ

- ព្យាយាមបង្កើតសហគ្រាសសង្គម ដោយផ្តល់សេវាផ្គត់ផ្គង់បុគ្គលិកដល់ក្រុមហ៊ុន សហគ្រាស
- ស្វែងរកគម្រោងពីអង្គការជាតិ និងអន្តរជាតិ ដើម្បីទទួលបានមូលនិធិ និងបន្សុីផែនការដែលមាន

## IV. ទិសដៅ និងវិធានការណ៍

| ទិសដៅ | វិធានការណ៍ |
|---|---|
| - កាត់បន្ថយអវត្តមាននិងការបោះបង់ការសិក្សារបស់សិស្ស | - ជំរុញលើកទឹកចិត្តសិស្សឲ្យយល់ពីសារប្រយោជន៍នៃភាសាអង់គ្លេសនិងកុំព្យូទ័រ ព្រមទាំងបំផុសចលនាមហាជនឲ្យចូលរួមតាមដានសកម្មភាពសិក្សារបស់កូនៗ |
| - បណ្តុះបណ្តាលបន្ថែមដល់គ្រូនៅតាមមូលដ្ឋាន | - ស្វែងរកដៃគូដើម្បីបញ្ជូនគ្រូទៅសិក្សាបន្ថែម និងបំប៉នគ្រូមួយដងក្នុងមួយខែនៅថ្ងៃចុងសប្តាហ៍ |
| - ដំឡើងអ៊ីនធឺណិតនៅគ្រប់មណ្ឌលសិក្សា | - ជាការបង្កភាពងាយស្រួលដល់ការសិក្សាស្រាវជ្រាវរបស់គ្រូ និងសិស្ស |
| - បន្តការសហការជាមួយមជ្ឈមណ្ឌលការងារខេត្ត និងអាជ្ញាធរ | - ចុះផ្សព្វផ្សាយពីឱកាសការងារដល់ពលរដ្ឋដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន |
| - ជំរុញលើកទឹកចិត្តយុវជនឲ្យរៀនជំនាញមុននឹងទៅធ្វើការ | - សហការជាមួយអង្គការ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនិងការងារ |

| | |
|---|---|
| - បន្តការជួយឧបត្ថម្ភកុំព្យូទ័រដល់សាលាចំណេះទូទៅ និងបច្ចេកទេស | - សហការជាមួយនាយកដ្ឋានតម្រង់ទិសនិងវិជ្ជាជីវៈនៃក្រសួងអប់រំ ដើម្បីកំណត់សាលាអាទិភាព |

## V. សន្និដ្ឋាន

ទោះបីជាស៊ីថេបមានបញ្ហាខាងហិរញ្ញវត្ថុក៏ដោយ ក៏ស៊ីថេបនៅតែខិតខំបន្តសកម្មភាព ដើម្បីបំពេញបេសសកម្ម និងគោលដៅរបស់ខ្លួនដែរ។ ចំពោះយុវជនធ្វើការចំណាកស្រុកទៅក្រៅប្រទេស ប្រាក់ខែនៅមានកម្រិត រោងចក្រ សហគ្រាសទទួលយកតែកម្មការិនីភាគច្រើន ពលរដ្ឋមានជំនាញនិងចំណេះនៅមានកម្រិតក៏ដោយ ក៏ស៊ីថេបបានខិតខំជម្នះរាល់បញ្ហាទាំងនេះដោយរៀបចំបណ្តុះបណ្តាលយុវជន និងពលរដ្ឋឱ្យបានយល់ដឹងពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបញ្ជូនអ្នកស្វែងរកការងារទៅតាមរោងចក្រជាច្រើនផងដែរ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលក៏មានគោលការណ៍តំឡើងប្រាក់ខែជារៀងរាល់ឆ្នាំដល់កម្មករកម្មការិនីផងដែរ ដែលនេះជាការកាត់បន្ថយការធ្វើចំណាកស្រុកមួយផងដែរ។ បន្ថែមលើសនេះ រាជរដ្ឋាភិបាលកំពុងជំរុញឱ្យមានការបណ្តុះបណ្តាលកម្លាំងជំនាញ១.៥លាននាក់ ដើម្បីបំពេញតម្រូវការរបស់ក្រុមហ៊ុន សហគ្រាស។

## VI. ឧបសម្ព័ន្ធ

**១. របាយការណ៍ហិរញ្ញវត្ថុសវនកម្មឆ្នាំ២០២៥**

**២. ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីអង្គការមិនមែនរដ្ឋាភិបាល**

**៣. រូបថតសកម្មភាពរបស់អង្គការ**

ធនាគារ កាថេ យូណៃធីត
Cathay United Bank

6 February 2026
11:55:6

Account Statement
Account : 03120216005638 Printed Datetime : 2026/02/06 11:55:04
Customer : 70038 CAMBODIA TEAM FOR EDUCATION PROGRAM
Currency : USD Printed By : KH0059
Statement Date: 2025/01/01 To 2025/12/31

| Book Date | Reference | Descript | Value Date | Debit | Credit | Closing Balance |
|---|---|---|---|---|---|---|
| | Balance at Period Start | | | | | 15,007.17 |
| 03 JAN 25 | TT25003NMBPF | CHQWTH 133740 | 03 JAN 25 | 14,900.00 | | 107.17 |
| 27 JAN 25 | FT25027DHS3J\HOF | TRF-FROM:HOU LI-ZEN | 27 JAN 25 | | 10,000.00 | 10,107.17 |
| 03 FEB 25 | TT250342TKB2 | CHQWTH 133741 | 03 FEB 25 | 10,000.00 | | 107.17 |
| 04 FEB 25 | FT250352NHPG\HOF | TRF-FROM:HOU LI-ZEN | 04 FEB 25 | | 3,100.00 | 3,207.17 |
| 06 FEB 25 | TT250372NWP5 | CHQWTH 133742 | 06 FEB 25 | 3,000.00 | | 207.17 |
| 25 FEB 25 | FT25056NXL90\HOF | TRF-FROM:HOU LI-ZEN | 25 FEB 25 | | 1,440.00 | 1,647.17 |
| 28 FEB 25 | TT250590QJFG | CHQWTH 133743 | 28 FEB 25 | 1,440.00 | | 207.17 |
| 28 FEB 25 | FT250590HNN9\HOF | TRF-FROM:HOU LI-ZEN | 28 FEB 25 | | 9,000.00 | 9,207.17 |
| 28 FEB 25 | FT25059DXK1S\HOF | TRF-FROM:HOU LI-ZEN | 28 FEB 25 | | 4,000.00 | 13,207.17 |
| 05 MAR 25 | TT250647XJMB | CHQWTH 133745 | 05 MAR 25 | 13,000.00 | | 207.17 |
| 21 MAR 25 | FT25080WFLGQ\HOF | TRF-FROM:HOU LI-ZEN | 21 MAR 25 | | 400.00 | 607.17 |
| 24 MAR 25 | TT25083TFF8W | CHQWTH 133746-CHHUN SOKSAN/092 87 48 23 | 24 MAR 25 | 507.00 | | 100.17 |
| 24 MAR 25 | FT25083P2SP1\HOF | TRF-FROM:HOU LI-ZEN | 24 MAR 25 | | 10,000.00 | 10,100.17 |
| 24 MAR 25 | FT25083169BT\HOF | TRF-FROM:HOU LI-ZEN | 24 MAR 25 | | 2,000.00 | 12,100.17 |
| 27 MAR 25 | TT25086W6KWX | CHQWTH 133747-CHHUN SOKSAN/092 87 48 23 | 27 MAR 25 | 300.00 | | 11,800.17 |
| 04 APR 25 | FT25094YXBTG | Transfer Out ( Payroll ) | 04 APR 25 | 9,968.00 | | 1,832.17 |
| 08 APR 25 | FT25098KPD8D\HOF | TRF-FROM:HOU LI-ZEN | 08 APR 25 | | 7,999.00 | 9,831.17 |
| 08 APR 25 | TT2509838QSD | CHQWTH 133749-HENG SREYPICH/081 6 20 339 | 08 APR 25 | 2,169.00 | | 7,662.17 |
| 08 APR 25 | FT25098PGGZD | Transfer Out ( Payroll ) | 08 APR 25 | 7,536.00 | | 126.17 |
| 18 APR 25 | FT251088Y8W3\HOF | TRF-FROM:HOU LI-ZEN | 18 APR 25 | | 3,800.00 | 3,926.17 |
| 21 APR 25 | TT251111YZ9Z | CHQWTH 133750-HENG SREYPICH/081 6 2 03 39 | 21 APR 25 | 2,800.00 | | 1,126.17 |
| 22 APR 25 | CURR.03120216005638.00000 | Cheque Issued Commission Dr | 22 APR 25 | 5.00 | | 1,121.17 |
| 05 MAY 25 | FT25125Z4CL0\HOF | TRF-FROM:HOU LI-ZEN | 05 MAY 25 | | 10,000.00 | 11,121.17 |
| 05 MAY 25 | FT251250R80G\HOF | TRF-FROM:HOU LI-ZEN | 05 MAY 25 | | 3,600.00 | 14,721.17 |
| 06 MAY 25 | FT251268W5BJ | Transfer Out ( Payroll ) | 06 MAY 25 | 10,382.00 | | 4,339.17 |
| 06 MAY 25 | TT25126T77RF | CHQWTH 135051-HENG SREYPICH/081 6 20 339 | 06 MAY 25 | 3,600.00 | | 739.17 |
| 26 MAY 25 | FT25146FDBY9\HOF | TRF-FROM:HOU LI-ZEN | 26 MAY 25 | | 10,000.00 | 10,739.17 |
| 26 MAY 25 | FT25146N64BQ\HOF | TRF-FROM:HOU LI-ZEN | 26 MAY 25 | | 2,400.00 | 13,139.17 |
| 04 JUN 25 | TT251556KBV9 | CHQWTH 135052-HENG SREYPICH/081 6 2 03 39 | 04 JUN 25 | 2,600.00 | | 10,539.17 |
| 04 JUN 25 | FT25155197FJ | Transfer Out ( Payroll ) | 04 JUN 25 | 9,734.00 | | 805.17 |
| 01 JUL 25 | FT25182T639L\HOF | TRF-FROM:HOU LI-ZEN | 01 JUL 25 | | 9,999.00 | 10,804.17 |
| 01 JUL 25 | FT25182B6M9Z\HOF | TRF-FROM:HOU LI-ZEN | 01 JUL 25 | | 3,001.00 | 13,805.17 |

| | | | | | | |
|---|---|---|---|---|---|---|
| 02 JUL 25 | FT2518318GXJ | Transfer Out ( Payroll ) | 02 JUL 25 | 11,692.00 | | 2,113.17 |
| 07 JUL 25 | TT251880XG50 | CHQWTH 135053-HENG SREYPICH/081 620 339 | 07 JUL 25 | 2,030.00 | | 83.17 |
| 15 JUL 25 | FT251967BCNL\HOF | TRF-FROM:HOU LI-ZEN | 15 JUL 25 | | 2,000.00 | 2,083.17 |
| 16 JUL 25 | TT25197N2GBY | CHQWTH 447026-HENG SREYPICH/081 620 339 | 16 JUL 25 | 2,000.00 | | 83.17 |
| 04 AUG 25 | FT25216X62G3\HOF | TRF-FROM:HOU LI-ZEN | 04 AUG 25 | | 10,000.00 | 10,083.17 |
| 04 AUG 25 | FT25216DFVC1\HOF | TRF-FROM:HOU LI-ZEN | 04 AUG 25 | | 6,300.00 | 16,383.17 |
| 04 AUG 25 | FT25216S64YJ\HOF | TRF-FROM:HOU LI-ZEN | 04 AUG 25 | | 1,200.00 | 17,583.17 |
| 04 AUG 25 | TT25216DJF1K | CHQWTH 447027-HENG SREYPICH/081 62 03 39 | 04 AUG 25 | 4,600.00 | | 12,983.17 |
| 04 AUG 25 | FT25216YCZ57 | Transfer Out ( Payroll ) | 04 AUG 25 | 12,660.00 | | 323.17 |
| 02 SEP 25 | FT25245XYBKQ\HOF | TRF-FROM:HOU LI-ZEN | 02 SEP 25 | | 10,000.00 | 10,323.17 |
| 02 SEP 25 | FT25245YK8QJ\HOF | TRF-FROM:HOU LI-ZEN | 02 SEP 25 | | 6,600.00 | 16,923.17 |
| 03 SEP 25 | TT25246GMWCW | CHQWTH 447028-HENG SREYPICH/081 62 03 39 | 03 SEP 25 | 2,840.00 | | 14,083.17 |
| 03 SEP 25 | FT25246NWP29 | Transfer Out ( Payroll ) | 03 SEP 25 | 13,525.00 | | 558.17 |
| 03 SEP 25 | TT252467Y5Q3\SP3 | POUV CHANRITH 010555735 | 03 SEP 25 | | 500.00 | 1,058.17 |
| 30 SEP 25 | FT25273TWS4G\HOF | TRF-FROM:HOU LI-ZEN | 30 SEP 25 | | 10,000.00 | 11,058.17 |
| 30 SEP 25 | FT252730JBFN\HOF | TRF-FROM:HOU LI-ZEN | 30 SEP 25 | | 3,100.00 | 14,158.17 |
| 03 OCT 25 | TT25276CY13V | CHQWTH 447029-HENG SREYPICH/081 62 03 39 | 03 OCT 25 | 1,200.00 | | 12,958.17 |
| 03 OCT 25 | FT25276GZRZK | Transfer Out ( Payroll ) | 03 OCT 25 | 12,817.00 | | 141.17 |
| 03 OCT 25 | FT25276SH0QW\HOF | TRF-FROM:HOU LI-ZEN | 03 OCT 25 | | 2,000.00 | 2,141.17 |
| 13 OCT 25 | TT25286HL4XV | CHQWTH 447031-HENG SREYPICH/081 62 03 39 | 13 OCT 25 | 1,820.00 | | 321.17 |
| 28 OCT 25 | FT253003KFBK\HOF | IR-FT253003KFBK\HOF-1/HOPEWAY GROUP LIMITED | 28 OCT 25 | | 7,104.00 | 7,425.17 |
| 30 OCT 25 | FT25303FS54S\HOF | OUR FT253003KFBK | 30 OCT 25 | | 5.00 | 7,430.17 |
| 31 OCT 25 | FT2530478NF9\HOF | TRF-FROM:HOU LI-ZEN | 31 OCT 25 | | 10,000.00 | 17,430.17 |
| 31 OCT 25 | FT25304FNS7Z\HOF | TRF-FROM:HOU LI-ZEN | 31 OCT 25 | | 3,790.00 | 21,220.17 |
| 03 NOV 25 | TT25307CY29W | CHQWTH 447032-HENG SREYPICH/081 62 03 39 | 03 NOV 25 | 7,874.00 | | 13,346.17 |
| 03 NOV 25 | FT25307VTKJ9 | Transfer Out ( Payroll ) | 03 NOV 25 | 13,004.00 | | 342.17 |
| 24 NOV 25 | FT2532569Y06\HOF | IR-FT2532569Y06\HOF-HOPEWAY GROUP LIMITED | 24 NOV 25 | | 1,988.00 | 2,330.17 |
| 28 NOV 25 | FT25332P21XP\HOF | OUR FT2532569Y06 | 28 NOV 25 | | 5.00 | 2,335.17 |
| 01 DEC 25 | FT25335CDQCF\HOF | TRF-FROM:HOU LI-ZEN | 01 DEC 25 | | 10,000.00 | 12,335.17 |
| 01 DEC 25 | FT25335XXR6W\HOF | TRF-FROM:HOU LI-ZEN | 01 DEC 25 | | 4,300.00 | 16,635.17 |
| 02 DEC 25 | TT25336B6NB9 | CHQWTH 447033-HENG SREYPICH/081 62 03 39 | 02 DEC 25 | 2,890.00 | | 13,745.17 |
| 02 DEC 25 | FT25336BZTJR | Transfer Out ( Payroll ) | 02 DEC 25 | 13,633.00 | | 112.17 |

| | | | | | |
|---|---|---|---|---|---|
| 22 DEC 25 | FT253535MNPH\HOF | IR-FT253535MNPH\HOF-HOPEWAY GROUP LIMITED | 22 DEC 25 | 1,988.00 | 2,100.17 |
| 23 DEC 25 | FT253571F8J8\HOF | OUR FT253535MNPH | 23 DEC 25 | 5.00 | 2,105.17 |
| 30 DEC 25 | FT25364LBBKZ\HOF | TRF-FROM:HOU LI-ZEN | 30 DEC 25 | 10,000.00 | 12,105.17 |
| 30 DEC 25 | FT25364VP3GP\HOF | TRF-FROM:HOU LI-ZEN | 30 DEC 25 | 3,188.00 | 15,293.17 |
| | Balance at Period End | | | | 15,293.17 |

# របាយការណ៍ចំណាយប្រចាំឆ្នាំ២០២៥

អង្គការក្រុមការងារកម្ពុជា ដើម្បីការអប់រំ

អត្រាប្តូរប្រាក់: ១ដុល្លា = ៤០០០រៀល

| N | ចំណាយប្រតិបត្តិការ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ចំណាយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | ចំណាយសប្បុរសធម៌ | 800,000 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 760,000 R | 200,000 R | 40,000 R | 3,843,960 R | 400,000 R | **6,043,960 R** |
| 2 | ចំណាយលើសេវាធនាគារ | 20,800 R | 20,840 R | 21,600 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | **63,240 R** |
| 3 | ចំណាយលើការកូពី ឯកសារនិងសៀវភៅសម្រាប់សិស្ស | 736,920 R | 216,360 R | 1,176,600 R | 53,600 R | 148,400 R | 34,560 R | 1,462,680 R | 1,021,520 R | 144,560 R | 161,520 R | 49,440 R | 38,880 R | **5,245,040 R** |
| 4 | ចំណាយលើសម្ភារថ្នាក់រៀន | 175,520 R | 2,000 R | 5,520 R | 0 R | 0 R | 141,000 R | 0 R | 504,000 R | 0 R | 332,000 R | 0 R | 160,000 R | **1,320,040 R** |
| 5 | ចំណាយលើការទិញឧបករណ៍សម្រាប់សរសេរកូដ | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 1,412,000 R | 2,279,520 R | 2,115,000 R | 2,513,080 R | 0 R | **8,319,600 R** |
| 6 | ចំណាយលើការរៀបចំកម្មវិធី | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 0 R | 9,783,080 R | 0 R | **9,783,080 R** |
| 7 | ចំណាយលើសេវាធានារ៉ាប់រង | 2,022,400 R | 2,025,680 R | 2,113,680 R | 2,127,920 R | 2,006,680 R | 2,004,920 R | 2,102,480 R | 2,107,360 R | 2,147,600 R | 2,197,000 R | 2,220,880 R | 2,297,480 R | **25,374,080 R** |
| 8 | ចំណាយលើសេវាអ៊ិនធើណេត | 720,000 R | 0 R | 5,280,000 R | 1,320,000 R | 0 R | 0 R | 0 R | 2,000,000 R | 0 R | 1,320,000 R | 0 R | 0 R | **10,640,000 R** |
| 9 | ចំណាយលើការថែទាំនិងជួសជុល | 0 R | 32,000 R | 32,000 R | 0 R | 1,986,400 R | 30,520 R | 1,783,000 R | 136,000 R | 32,000 R | 124,800 R | 952,000 R | 1,218,520 R | **6,327,240 R** |
| 10 | ចំណាយផ្សេងៗ | 240,000 R | 6,337,000 R | 0 R | 98,640 R | 368,000 R | 55,000 R | 166,000 R | 3,645,520 R | 937,200 R | 131,600 R | 796,960 R | 28,000 R | **12,803,920 R** |
| 11 | ចំណាយលើសម្ភារការិយាល័យ | 472,000 R | 1,647,600 R | 403,440 R | 696,920 R | 2,637,000 R | 241,000 R | 1,829,320 R | 84,520 R | 19,000 R | 15,520 R | 1,272,000 R | 62,000 R | **9,380,320 R** |
| 12 | ចំណាយលើការជួលទីតាំង | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | 2,000,000 R | **24,000,000 R** |
| 13 | ចំណាយលើប្រាក់ខែ | 42,744,000 R | 44,256,000 R | 45,080,000 R | 72,480,000 R | 43,012,000 R | 40,388,000 R | 46,768,000 R | 50,640,000 R | 54,100,000 R | 51,268,000 R | 52,016,000 R | 54,532,000 R | **597,284,000 R** |
| 14 | ចំណាយលើសេវាសន្តិសុខ | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 440,000 R | 560,000 R | **5,400,000 R** |
| 15 | ការចំណាយលើសម្ភារផ្គត់ផ្គង់ | 0 R | 0 R | 0 R | 0 R | 0 R | 13,000 R | 27,000 R | 0 R | 30,000 R | 0 R | 0 R | 0 R | **70,000 R** |
| 16 | ការចំណាយលើអាហារូបករណ៍ | 0 R | 420,000 R | 0 R | 0 R | 0 R | 420,000 R | 0 R | 0 R | 400,000 R | 400,000 R | 820,000 R | 400,000 R | **2,860,000 R** |
| 17 | ពន្ធ | 450,320 R | 491,440 R | 458,240 R | 2,310,480 R | 622,560 R | 371,120 R | 643,840 R | 1,048,960 R | 1,294,520 R | 1,043,680 R | 1,083,360 R | 1,064,680 R | **10,883,200 R** |
| 18 | ការចំណាយលើការបណ្តុះបណ្តាលសម្រាប់គ្រូ | 1,142,000 R | 336,000 R | 1,033,520 R | 0 R | 288,000 R | 276,000 R | 384,000 R | 1,082,000 R | 324,000 R | 408,000 R | 360,000 R | 216,000 R | **5,849,520 R** |
| 19 | ចំណាយលើការធ្វើដំណើរពេលចុះពិនិត្យតាមមណ្ឌលសិក្សា | 1,010,800 R | 3,431,600 R | 1,777,600 R | 2,839,520 R | 493,840 R | 445,680 R | 4,880,200 R | 1,368,600 R | 1,327,480 R | 3,053,280 R | 2,607,240 R | 2,272,080 R | **25,507,920 R** |
| 20 | ការចំណាយលើការប្រើប្រាស់អគ្គិសនី | 1,289,840 R | 1,594,960 R | 1,293,800 R | 1,441,600 R | 1,481,360 R | 1,593,000 R | 1,449,720 R | 1,579,120 R | 1,619,400 R | 1,241,120 R | 1,462,800 R | 1,652,640 R | **17,699,360 R** |
| 21 | ចំណាយលើកម្មវិធីបិទវគ្គសិក្សា | 216,520 R | 1,359,000 R | 69,520 R | 0 R | 0 R | 0 R | 252,520 R | 785,000 R | 60,000 R | 0 R | 0 R | 0 R | **2,742,560 R** |
| | **ចំណាយសរុប** | **54,481,120 R** | **64,610,480 R** | **61,185,520 R** | **85,808,680 R** | **55,484,240 R** | **48,453,800 R** | **64,188,760 R** | **70,614,600 R** | **67,355,280 R** | **66,291,520 R** | **82,220,800 R** | **66,902,280 R** | **787,597,080 R** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៨៨៩០ ប្រក

# ប្រកាស
## ស្ដីពី
## ការចុះឈ្មោះក្នុងបញ្ជីអង្គការមិនមែនរដ្ឋាភិបាល

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះលេខ០០១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ របស់លោក **ឈុន សុខសាន្ត** ប្រធានអង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ

### សម្រេច

**ប្រការ ១ ..**

ត្រូវបានចុះឈ្មោះ **អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ** ក្នុងបញ្ជីអង្គការមិនមែនរដ្ឋាភិបាល នៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្ដាលតាំងនៅផ្ទះលេខ៤D១ ផ្លូវជាតិលេខ៦ ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

**ប្រការ ២ ..**

**អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣ ..**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តសៀមរាប ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីអង្គការដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ២០១៦

ឧ.រដ្ឋមន្ត្រី/
រដ្ឋលេខាធិការ

ប៉ុល_លឹម

**កន្លែងទទួល:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិ នៃកម្ពុជា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ៧០៥ សជណ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ អង្គារ ៦ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៩

**ជម្រាបមក**
**លោក ឈុន សុខសាន្ត**
**ប្រធានអង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ**

**កម្មវត្ថុ** ៖ អំពីសំណើសុំប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលអង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ។

**យោង** ៖- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- ប្រកាសលេខ ៦៦៩០ ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ០៨០ អ.ក.ក.ក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ របស់អង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃអនុញ្ញាតឲ្យអង្គការក្រុមការងារកម្ពុជាដើម្បីការអប់រំ ប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលមកតាំងនៅផ្ទះលេខ៨១៨ ផ្លូវលោកតាណឹយ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប តាមលិខិតបញ្ជាក់លេខ០៨៨៥/១៩ ស.ស.ល.ក.រ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ របស់សាលាសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន-ហ៊ុន**

**ចម្លងជូន ៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
"ដើម្បីជូនជ្រាប"
-សាលាខេត្តសៀមរាប
"ដើម្បីមុខការ"
-ឯកសារ - កាលប្បវត្តិ

## សកម្មភាពបំប៉នគ្រូប្រចាំខែ



## សកម្មភាពរៀននិងបង្រៀននៅតាមមណ្ឌលសិក្សា







## សកម្មភាពចុះឈ្មោះស្វែងរកការងារនៅតាមទីតាំងភូមិសាស្ត្រក្នុងខេត្តសៀមរាប



